**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤១៧ សហវ.ប្រក.ន.គ.ស

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១ ស្តីពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ, លេខ ២ ស្តីពីរបាយការណ៍លំហូរសាច់ប្រាក់ និង លេខ ១២ ស្តីពីសន្និធិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៧ អ.ស.ហ.ប្រក.ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម
- យោងតាមសំណើរបស់និយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

### ប្រការ១._

ត្រូវបានដាក់ឱ្យអនុវត្តនូវស្តង់ដាគណនេយ្យសាធារណៈកម្ពុជាចំនួន៣ ដូចខាងក្រោម៖

១. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១ ស្តីពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ

២. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ២ ស្តីពីរបាយការណ៍លំហូរសាច់ប្រាក់ និង

៣. ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ១២ ស្តីពីសន្និធិ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាន "ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ" ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ។

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ២._

និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចចេញគោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តង់ដាគណនេយ្យដល់គណនេយ្យករសាធារណៈ និងតួអង្គពាក់ព័ន្ធ តាមការចាំបាច់។

ក្នុងករណីចាំបាច់ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អាចធ្វើបច្ចុប្បន្នភាពស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដើម្បីឱ្យស្របតាមបរិបទអន្តរជាតិ។

### ប្រការ៣._

អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងតួនាទីជាគណនេយ្យករសាធារណៈ ត្រូវដាក់បង្ហាញជាបណ្តើរៗនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ រៀបចំរបាយការណ៍លំហូរសាច់ប្រាក់ និងធ្វើប្រព្រឹត្តិកម្មគណនេយ្យសម្រាប់សន្និធិរបស់រាជរដ្ឋាភិបាល ឱ្យស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ។

ចាប់ពីកាលបរិច្ឆេទអនុវត្តប្រកាសនេះ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវរៀបចំហេដ្ឋារចនាសម្ព័ន្ធគណនេយ្យសាធារណៈឱ្យបានរួចរាល់ និងត្រូវចាប់ផ្ដើមអនុវត្តជាបណ្ដើរៗ សម្រាប់ការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ ស្របតាមយុទ្ធសាស្ត្រស្ដីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១។

**ប្រការ៤.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួង អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រសួង ស្ថាប័នដូចបានកំណត់ក្នុងប្រការ៤ និងគ្រប់អ្នកពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ កើត ខែ កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ